**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង

យោងតាមគេហទំព័រក្រសួងការងារប្រទេសថៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ និងសាធារណជនជ្រាបអំពីបញ្ជីឈ្មោះក្រុមហ៊ុនស្របច្បាប់របស់ថៃ ដែលទទួលស្គាល់ដោយក្រសួងការងារប្រទេសថៃចំនួន ៣១៧ក្រុមហ៊ុន (ឧបសម្ព័ន្ធ ១)។ សូមបញ្ជាក់ថា មានតែក្រុមហ៊ុនចំនួន ៣១៧ ប៉ុណ្ណោះ ដែលមានសិទ្ធិសម្របសម្រួលជាមួយនិយោជក ក្នុងការដំណើរការឯកសាររបស់បងប្អូនពលករ ដើម្បីស្នើសុំប័ណ្ណអនុញ្ញាតការងារ (Work Permit) លិខិតអនុញ្ញាតស្នាក់នៅ (Stay Permit) ឬផ្លាស់ប្តូរកន្លែងធ្វើការបានដោយស្របតាមច្បាប់ប្រទេសថៃ។

ដោយឡែកសម្រាប់បងប្អូននៅកម្ពុជា ដែលមានបំណងទៅធ្វើការនៅប្រទេសថៃ សូមចុះឈ្មោះជាមួយទីភ្នាក់ងារជ្រើសរើសឯកជនស្របច្បាប់របស់កម្ពុជា ដែលទទួលស្គាល់ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំនួន ៧៧ក្រុមហ៊ុន (ឧបសម្ព័ន្ធ ២) ដែលមានសិទ្ធិសម្របសម្រួលជាមួយក្រុមហ៊ុនថៃ ឬនិយោជក ក្នុងការដំណើរការសំណុំឯកសារមុនចេញដំណើរទៅធ្វើការនៅប្រទេសថៃ។

ក្រសួងសូមក្រើនរំលឹកដល់បងប្អូន កុំចុះឈ្មោះ ឬទៅធ្វើការតាមរយៈបុគ្គល ឬមេខ្យល់ណាមួយ ឬក្រុមហ៊ុនដែលមិនមានឈ្មោះក្នុងឧបសម្ព័ន្ធទាំង ២នេះ ជាដាច់ខាត ដើម្បីជៀសវាងការខាតបង់ពេលវេលា ប្រាក់កាស និងអាចធ្លាក់ខ្លួនជាជនរងគ្រោះ នៃអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

ករណីបងប្អូន និងសាធារណជនទាំងអស់ដែលទទួលបានព័ត៌មានអំពីការឆបោក ឬការកេងប្រវ័ញ្ចកម្លាំងពលកម្ម ឬរងគ្រោះដោយប្រការណាមួយ សូមប្តឹងទៅនាយកដ្ឋានមុខរបរនៃក្រសួងការងារថៃ តាមរយៈលេខ ១៥០៦ រួចបន្តចុចលេខ ២ ឬ Hotline ១៦៩៤ និងប្តឹងមកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈកម្ពុជា តាមរយៈប្រព័ន្ធ Hotline លេខ ១២៨៦ ឬ ១២៩៧ ឬពិនិត្យមើលបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនដែលមាននៅក្នុងគេហទំព័ររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (https://www.mlvt.gov.kh) ឬប្រព័ន្ធតាមដានពលករទេសន្តរប្រវេសន៍ (https://tracking.ocwc.co)។ ម្យ៉ាងវិញទៀត សាធារណជន ក៏អាចដាក់បណ្តឹងអនាមិក ដោយមិនតម្រូវឱ្យបញ្ជាក់អត្តសញ្ញាណរបស់ម្ចាស់បណ្តឹងឡើយតាមរយៈតំណភ្ជាប់ (https://feedback.mlvt.gov.kh) ឬអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនជ្រាបជាព័ត៌មាន។

ថ្ងៃចន្ទ ១២កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤

ប្រអប់បណ្តឹងអនាមិក